រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០២៣...សហក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ផលប៉ះពាល់តំបន់ និងជនស៊ីវិលកម្ពុជា
## ដោយអំពើឈ្លានពានរបស់រដ្ឋាភិបាល និងយោធាថៃ មកលើដែនអធិបតេយ្យកម្ពុជា
## ពីម៉ោង៧ព្រឹក ដល់ម៉ោង១រសៀល ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៥

គិតពីថ្ងៃទី៧ ខែធ្នូ រហូតដល់ម៉ោង១រសៀល ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៥នេះ អំពើឈ្លានពានរបស់រដ្ឋាភិបាល និងយោធាថៃ មកលើដែនអធិបតេយ្យកម្ពុជា ជាពិសេសការផ្លោង និងទម្លាក់គ្រាប់តូចធំគ្រប់ប្រភេទចូលតំបន់ស៊ីវិល បានបណ្តាលឱ្យប្រជាពលរដ្ឋកម្ពុជាស្លាប់១៩នាក់ របួស៧៩នាក់ ខូចខាតផ្ទះសំបែង ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមានជនភៀសសឹកកើនឡើងទាំងនៅក្នុងខេត្តរងការឈ្លានពាន និងខេត្តផ្សេងៗទៀត។ **គិតពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១រសៀល ថ្ងៃទី២១ ខែធ្នូ ផលប៉ះពាល់មានដូចខាងក្រោម៖**

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖** ពុំមានពលរដ្ឋស្លាប់ និងរបួសទេ។

**២-ករណីពលរដ្ឋនៅជំរំសុវត្ថិភាព៖** មានជនភៀសសឹកសរុប **៥១៧.៨១៥នាក់** ក្នុងនោះស្រ្តី ២៦៩.៧៦៨នាក់ និងកុមារ១៦៥.២១៦នាក់។ តួលេខនេះ អាចមានការប្រែប្រួលជាបន្តបន្ទាប់ទៀត។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល និងការខូចខាតជាអាទិ៍៖** ពុំមានការខូចខាតថ្មី។ ជាបឋម គិតពីថ្ងៃទី៧ ខែធ្នូមក ការខូចខាតសរុបមាន ផ្ទះប្រជាពលរដ្ឋ៧៦ខ្នង សាលារៀន៥ទីតាំង មណ្ឌលសុខភាព១ទីតាំង ផ្សារ១កន្លែង ប្រាសាទបុរាណមួយចំនួន វត្ត៥ទីតាំង សាលាឆទាន១ទីតាំង កុដិ១ទីតាំង អគារគយ និងរដ្ឋាករ១អគារ អគារឯកជន៩ទីតាំង សណ្ឋាគារ៣ទីតាំង មណ្ឌលកសិកម្មសហគមន៍១ទីតាំង ស្ពានថ្ម២កន្លែង ស្ពានដែក១ ស្ពានបុរាណ១ ក្បាលស្ពាន១ ស្ថានីយ៍ប្រេង១ទីតាំង មធ្យោបាយដឹកជញ្ជូន២៨គ្រឿង ឃ្លាំងរថយន្ត១ និងឃ្លាំងទិញដំឡូង១ទីតាំង។ មានប្រជាជនកម្ពុជាជាងកន្លះលាននាក់ រួមទាំងស្ត្រី និងកុមារ កំពុងរងទុក្ខលំបាក បន្ទាប់ពីបង្ខំចិត្តចាកចោលផ្ទះសំបែង និងសាលារៀន គេចពីគ្រាប់កាំភ្លើង គ្រាប់ផ្លោងតូចធំ និងការទម្លាក់គ្រាប់ពីយន្តហោះ F-16 របស់ថៃ ដែលបំផ្លាញផ្ទះសំបែង និងភូមិករពួកគាត់ជាបន្តបន្ទាប់រួចទៅហើយ។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គាំទ្រពេញទំហឹង គោលជំហរដែល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានបញ្ជាក់ចំពោះប្រេសិតពិសេសចិន។ យើងសាទរក្រៃលែង កិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន ស្តីពីស្ថានភាពបច្ចុប្បន្ន រវាងកម្ពុជា-ថៃ នៅប្រទេសម៉ាឡេស៊ី នាថ្ងៃទី២២ ខែធ្នូនេះ ដើម្បីបង្កើនការយោគយល់ ជំនឿទុកចិត្ត ជំរុញបន្ថយភាពតានតឹង ស្តារឡើងវិញសន្តិភាព ស្ថិរភាព និងទំនាក់ទំនងភាពជាអ្នកជិតខាងល្អ។ យើងមានសុទិដ្ឋិនិយមថា ភាគីថៃ នឹងបង្ហាញភាពស្មោះត្រង់ អនុវត្តគោលការណ៍សន្តិវិធី ការសន្ទនា និងផ្លូវការទូត ស្របតាមយន្តការដែលមានស្រាប់ ច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ដើម្បីនាំមកនូវសន្តិភាពសម្រាប់ប្រជាជនទាំងសងខាង ដែលក៏ជាវត្ថុបំណងរួមរបស់ប្រជាជាតិក្នុងតំបន់ និងពិភពលោក។

**ក្រសួងមហាផ្ទៃ** មានមោទនភាពចំពោះកូនខ្មែរគ្រប់រូប ដែលរំឭកស្មារតីប្រកៀកស្មាគាំទ្រយុទ្ធសាស្រ្តការពារជាតិរបស់ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត**។ មហាកម្លាំងសាមគ្គីនេះ បានផ្តល់ថាមពលដ៏មហិមាជូនកងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ និងនគរបាលការពារព្រំដែននៃក្រសួងមហាផ្ទៃ ដែលកំពុងប្រយុទ្ធការពារបូរណភាពទឹកដី។ សូមជនរួមជាតិបន្តពង្រឹងស្មារតីព្រលឹងខ្មែរតែមួយនេះឱ្យបានឋិតនៅជានិរន្តរ៍។

ថ្ងៃអាទិត្យ ២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៥